# វិទ្យាស្ថានជាតិអប់រំ

NATIONAL INSTITUTE OF EDUCATION

## សន្និសីទស្រាវជ្រាវថ្នាក់ជាតិ លើកទី១ ឆ្នាំ២០២៦

## ប្រធានបទ៖ គម្រូវការអាទិភាពនៃការគ្រប់គ្រងការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ដើម្បីលើកកម្ពស់បំណិនភាពជាអ្នកដឹកនាំឌីជីថល

បង្ហាញដោយ៖ លោក ឈួន ឌី

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦

# សាវតារ និងចំណោទបញ្ហានៃការស្រាវជ្រាវ

បដិវត្តន៍ឧស្សាហកម្មទី៤ បាននាំមកនូវការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសកល ដែលមានឥទ្ធិពលលើគ្រប់ទិដ្ឋភាពនៃសង្គមមនុស្ស ( Bradley et al., 2015; Yokoi et al., 2019 )។

សារសំខាន់ និងតួនាទី នៃភាពជាអ្នកដឹកនាំឌីជីថល ត្រូវបានលេចឡើងក្នុងដំណើរការផ្លាស់ប្តូរសម្រាប់ការសាងនូវរបៀបគ្រប់គ្រងថ្មី អភិបាលកិច្ច ការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត ឬការដោះស្រាយបញ្ហានានា ដើម្បីប្រកួតប្រជែង និងធានានិរន្តភាពនិងវឌ្ឍភាពរបស់អង្គភាព/ស្ថាប័ន ( Yokoi et al., 2019; Hoy & Mikel, 2010; Petry, 2016; រាជរដ្ឋាភិបាល, ២០២១ )។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល នៅឆ្នាំ២០៣០ និងឆ្នាំ២០៥០

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា

គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ និងសកម្មភាពអាទិភាព។

# សារៈតារ និងចំណោទបញ្ហានៃការស្រាវជ្រាវ (ត)

ចក្ខុវិស័យរបស់សាលារៀនកម្ពុជា ឆ្នាំ២០៣០ គឺការប្រើប្រាស់បច្ចេកវិទ្យាក្នុងការដឹកនាំគ្រប់គ្រងការរៀន និងបង្រៀន ដើម្បីបង្កើតនូវបរិយាកាសសិក្សារៀនសូត្រប្រកបដោយសុវត្ថិភាព និងគុណភាពខ្ពស់ តាមរយៈការបង្កើតឱ្យមានបន្ទប់រៀនវៃឆ្លាតដោយបំពាក់ធនធានអប់រំ និងបច្ចេកវិទ្យា (អយក, ២០១៩)។

ការចាប់យក និងការសម្របខ្លួន និងទាញយកអត្ថប្រយោជន៍ពីការរីកចម្រើនបច្ចេកវិទ្យាឌីជីថល នៅកម្ពុជាមានវឌ្ឍនភាពយឺតយ៉ាវជាងប្រទេសក្នុងតំបន់ និងសកលលោក (N.123/180)។ ប្រជាជនកម្ពុជា ប្រមាណ **៣០ភាគរយ** ប៉ុណ្ណោះ ដែលមានជំនាញឌីជីថលកម្រិតមូលដ្ឋាន (រាជរដ្ឋាភិបាល, ២០២១)។ គ្រូបង្រៀន និងនាយកសាលាត្រឹមតែ **១៣ភាគរយ** និងមន្ត្រីអប់រំ **២២ភាគរយ**ប៉ុណ្ណោះ មានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញមុខងារការងារ (UNICEF & MoEYS, 2021)

គម្លាតនេះ បង្ហាញពីតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍភាពជាអ្នកដឹកនាំឌីជីថលក្នុងចំណោមគ្រូបង្រៀន ដើម្បីធ្វើទំនើបកម្មប្រព័ន្ធអប់រំ និងបង្កើតសមត្ថភាពប្រកួតប្រជែងផ្នែកសង្គមសេដ្ឋកិច្ចទាំងក្នុងតំបន់និងពិភពលោក (MoEYS, 2020)។

# គោលបំណង និងសំណួរការស្រាវជ្រាវ

## គោលបំណងស្រាវជ្រាវ

សិក្សាអំពីតម្រូវការអាទិភាព នៃការគ្រប់គ្រងការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ដើម្បីលើកកម្ពស់បំណិនភាពជាអ្នកដឹកនាំឌីជីថល។

## សំណួរស្រាវជ្រាវ

តើការគ្រប់គ្រងការសិក្សា នៅមធ្យមសិក្សាទុតិយភូមិ ដើម្បីលើកកម្ពស់បំណិនភាពជាអ្នកដឹកនាំឌីជីថល មានតម្រូវការអាទិភាពកម្រិតណា ?

# ក្របខណ្ឌគោលគំនិតនៃការគ្រប់គ្រងការសិក្សា

**ការគ្រប់គ្រងការសិក្សា** សំដៅលើការអភិវឌ្ឍកម្មវិធីសិក្សា ការបង្រៀន និងរៀន និងការវាយតម្លៃការសិក្សា (Fullan, 2014; Hangchuon, 2017; Quintero, 2003; Seak, 2022; Wiengin et al, 2023)។

# ក្របខណ្ឌគោលគំនិតនៃការគ្រប់គ្រងការសិក្សា




- ❖ បំណងកម្មវិធីសិក្សា
- ❖ សៀវភៅសិក្សាគោល

- ❖ វិធីសាស្ត្របង្រៀន
- ❖ ហេដ្ឋារចនាសម្ព័ន្ធ និងធនធានសិក្សាឌីជីថល
- ❖ សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន

- ❖ ឧបករណ៍វាយតម្លៃ
- ❖ ការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ

# ក្របខណ្ឌគោលគំនិតនៃបំណិនភាពជាអ្នកដឹកនាំឌីជីថល

**បំណិនភាពជាអ្នកដឹកនាំឌីជីថល** សំដៅលើបំណិនអក្ខរកម្មឌីជីថល បំណិននវានុវត្តន៍ឌីជីថល និងបំណិនអន្តរបុគ្គល (Garland & Tadeja, 2013; ISTE, 2014; Petry, 2016; Promsri, 2019; Sheninger, 2014; Zhu, 2015។

# ក្របខណ្ឌគោលគំនិតនៃបំណិនភាពជាអ្នកដឹកនាំឌីជីថល

❖ ចក្ខុវិស័យ

❖ នវានុវត្តន៍វិធីសាស្ត្របង្រៀន

❖ បំណិនសិក្សាវិជ្ជាជីវៈ




❖ អក្ខរកម្មឌីជីថល

❖ ភាពជាពលរដ្ឋឌីជីថល

❖ បំណិនទំនាក់ទំនង

❖ បំណិនសហការ

# ការកំណត់តម្រូវការអាទិភាព

- សន្ទស្សន៍តម្រូវការអាទិភាព ( $PNI_{modified}$ ) គឺជាសូចនាករនៃតម្រូវការអាទិភាព។ លទ្ធផលដែលមានតម្លៃខ្ពស់បង្ហាញនូវអាទិភាពកាន់តែខ្ពស់ដែលត្រូវការកែលម្អ ឬរកដំណោះស្រាយ។ តម្រូវការជាគម្លាតរវាងលទ្ធផលបច្ចុប្បន្ន និងការចង់បាននាពេលអនាគត ( Altschuld & Watkins, 2014; Kaufman, 2000 )។
- ការកំណត់នូវគម្លាតរវាងស្ថានភាពបច្ចុប្បន្ន និងការចង់ប្រែក្លាយនាពេលអនាគត ជាមូលដ្ឋានស្វែងរកដំណោះស្រាយឆ្លើយតបនឹងតម្រូវការ ( Kaufman, 2000 )។
- $PNI_{modified}$ ត្រូវបានគណនាដោយរូបមន្ត ( Wongwanich, 2019 )៖

$$PNI = (I-D)/D$$

I សំដៅលើកម្រិតនៃការចង់ប្រែក្លាយដើម្បីឱ្យសម្រេច

D សំដៅលើកម្រិតស្ថានភាពបច្ចុប្បន្ន

# វិធីសាស្ត្រស្រាវជ្រាវ៖ នីតិវិធីស្រាវជ្រាវ (PROCEDURE DIAGRAM)

| ដំហាន | ការប្រមូលទិន្នន័យ | ការវិភាគទិន្នន័យ | លទ្ធផល |
|---|---|---|---|
| ក្របខណ្ឌគោលគំនិត | ○ សិក្សាលើឯកសារ<br>○ វាយតម្លៃ IOC (n=5) | ○ សំយោគ និងវិភាគខ្លឹមសារ<br>○ វិភាគស្ថិតិ (មធ្យមភាគ) | ក្របខណ្ឌគោលគំនិត |
| ទិន្នន័យបរិមាណវិស័យ | ○ កម្រងសំណួរ<br>  ○ វាយតម្លៃ IOC (n=5)<br>  ○ សាកល្បង (n=40)<br>○ ភាគសំណាក (n=230) | ○ មធ្យមភាគ<br>○ ស្ថិតិពណ៌នា (ភាគរយ មធ្យមភាគ គម្លាតស្តង់ដា) | ស្ថានភាពបច្ចុប្បន្ន និងតម្រូវការ (បរិមាណវិស័យ) |
| ការកំណត់តម្រូវការអាទិភាព | ○ គណនា PNI=(I-D)/D | ○ វិភាគ និងកំណត់ចំណាត់ថ្នាក់ PNI | តម្លៃសន្ទស្សន៍ PNI នៃតម្រូវការអាទិភាព |

# លទ្ធផលរួមនៃការស្រាវជ្រាវ






# លទ្ធផលនៃការស្រាវជ្រាវ ៖ ការអភិវឌ្ឍកម្មវិធីសិក្សា






# លទ្ធផលនៃការស្រាវជ្រាវ ៖ ការបង្រៀននិងរៀន






# លទ្ធផលនៃការស្រាវជ្រាវ ៖ ការវាយតម្លៃការសិក្សា






# សេចក្ដីសន្និដ្ឋាន

ការគ្រប់គ្រងការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ដើម្បីលើកកម្ពស់បំណិនភាពជាអ្នកដឹកនាំឌីជីថល មានតម្រូវការអាទិភាពខ្លាំង (០.៣៦៧) ក្នុងនោះការវាយតម្លៃការសិក្សា (**០.៣៨៥**) ការអភិវឌ្ឍកម្មវិធីសិក្សា (០.៣៦៧) ការបង្រៀននិងរៀន (០.៣៥៥) បំណិនឌីជីថល (០.៣៩៣) បំណិននវានុវត្តន៍ឌីជីថល (០.៣៧១) និងបំណិនអន្តរបុគ្គល (០.៣៦១)។ លទ្ធផលនេះ បង្ហាញថាការវាយតម្លៃការសិក្សា ជាអាទិភាពចម្បងនៃការគ្រប់គ្រងការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ដើម្បីលើកកម្ពស់បំណិនភាពជាអ្នកដឹកនាំឌីជីថល ដោយផ្ដោតលើបំណិនឌីជីថល។

ការសិក្សានេះ នឹងរួមចំណែកជាទស្សនាទានដល់អ្នករៀបចំគោលនយោបាយ គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ គ្រូបង្រៀន និងសាលារៀន នូវការរៀបចំកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀន កែលម្អក្របខណ្ឌកម្មវិធីសិក្សា និងផ្ដល់ការគាំទ្រនានា ដើម្បីជំរុញការអនុវត្តរបស់គ្រូបង្រៀនឱ្យកាន់តែមានភាពច្នៃប្រឌិត និងលើកកម្ពស់បរិស្ថានសិក្សាស្របតាមនិន្នាការអប់រំនាសតវត្សរ៍ទី២១។

# សូមអរគុណ!